# TTB-0030

## សេចក្តីផ្តើម

**ក៖** អស់លោកលោកស្រីប្រិយមិត្តកំពុងស្តាប់កម្មវិធីសិក្សាតាមប្រពន្ធ័ព្រះគម្ពី  កម្មវិធីយើងខ្ញុំមានបិតិសោមនស្សយ៉ាងខ្លាំងដែលលោកអ្នកបានចំណាយពេលវេលាដ៏មានតំលៃស្តាប់កម្មវិធីរបស់យើងខ្ញុំកម្មវិធីសិក្សាតាមប្រពន្ធ័ព្រះគម្ពីផ្តល់សារៈប្រយោជន៏ដល់លោកអ្នកអោយស្គាល់ព្រះជាម្ចាស់និងលូតលាស់ខាងជំនឿរហូតដល់លោកអ្នកអាចបង្កើតផលផ្លែជាប់លាប់ថ្វាយព្រះអង្គម្ចាស់បាន។

**ខ៖** លោក លោកស្រីនិងប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី ក្នុងវគ្គសិក្សាកន្លងទៅយើងបានសិក្សាអំពីសេចក្តីពិតនានា

ដូចបានសំដែងនៅក្នុងព្រះគម្ពីប៊ីបរួចមកហើយយើងខ្ញុំសូមអញ្ជើញអស់លោកអ្នកសិក្សាមេរៀនរបស់យើងជាបន្តទៅទៀត  នៅកាណ្ឌលោកុប្បត្តិលោកុប្បត្តិ១៦៖៦ដល់១៧៖៧ នៅក្នុងជំពូក១៦យើងពិចារណាពីហេតុការណ៏ ដែលនាងហាការរត់ចេញពីផ្ទះ និងសេចក្តីល្បួងដល់លោកអាប្រាហាំវីឯនៅក្នុងជំពូកទី១៧វិញយើងសិក្សាអំពីព្រះជាម្ចាស់ប្រទានឈ្មោះថ្មីដល់លោកអាប្រាហាំ និងការតាំងសញ្ញាថ្មីជាមួយរូបលោក។

**គ៖** ចាំអស់លោកអ្នកបងប្អូនដើម្បីអោយកាន់តែយល់ច្បាស់នៅមេរៀបរបស់យើងនៅថ្ងៃនេះ សូមបានចូលរួមសណ្តាប់ដូចតទៅ---



Page **1** of **15**

# លោកុប្បត្តិ១៦:៦និង១៧:៧

## នាងហាការរត់ចេញពីផ្ទះ

**នោះអាប់រ៉ាមគាត់ឆ្លើយនឹងសារ៉ាយថាមើលបាវស្រីឯងវានៅក្នុងអំណាចរបស់ឯងស្រាប់ ហើយចូរប្រព្រឹត្តនឹងវាតាមតែឯងគិតឃើញថាយ៉ាងណាស្រួលចុះ នោះសារ៉ាយក៏ប្រព្រឹត្តនឹងនាងដោយ តឹងរ៉ឹងណាស់ បានជានាងរត់ចេញពីគាត់ទៅ លោកុប្បត្តិ១៦:៦។**

នាងហាការសម្រេចចិត្តរត់ចេញពីផ្ទះរបស់ចៅហ្វាយខ្លួន។ការរត់ចេញពីផ្ទះនេះអាចបណ្ដាលអោយនាងស្លាប់ ឯកូននៅក្នុងផ្ទៃរបស់នាងក៏ស្លាប់ទៅជាមួយនឹងនាង ដែរ។

**ទេវតានៃព្រះយេហូវ៉ាទ្រង់ឃើញនាងនៅទីរហោស្ថានជិតក្បាលទឹក១ គឺជាក្បាលទឹកដែលនៅតាមផ្លូវទៅឯស្រុកស៊ើរ លោកុប្បត្តិ១៦:៧។**

ខ្ញុំជឿថាទេវតាដែលលេចមកអោយនាងហាការឃើញមិនមែនជានរណាក្រៅពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់មិនទាន់យាង មកប្រសូតនៅផែនដីនោះទេ។ បុគ្គលិកលក្ខណៈរបស់ព្រះអង្គ គឺទ្រង់តែងតែយាងទៅរកមនុស្សដែលបាត់បង់។នាងហាការបានធ្វើដំណើរឆ្ងាយពីផ្ទះមហាសែនឆ្ងាយ។ ព្រះអង្គយាងទៅរកនាងដែលកំពុង តែបាត់បង់នោះ។

**ទ្រង់មានបន្ទូលសួរថា នែហាការបាវសារ៉ាយអើយ តើឯងមក ពីណា ហើយគិតទៅឯណាហ្នឹងនាងទូលឆ្លើយនឹងទេវតាថាខ្ញុំម្ចាស់រត់ចេញពីសារ៉ាយជាចៅហ្វាយរបស់ខ្ញុំម្ចាស់មក នោះ ទេវតានៃព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅនាងថា**



Page **2** of **15**

**ចូរវិលទៅឯចៅ ហ្វាយឯងវិញទៅ ហើយចុះចូលនឹងអំណាចរបស់គាត់វិញ ទេវតានៃព្រះយេហូវ៉ាក៏មានបន្ទូលទៅនាងថាអញនឹងចម្រើនពូជឯងអោយមានសន្ធឹកឥតគណនា លោកុប្បត្តិ១៦:៨-១០។**

នៅក្នុងគម្ពីរកាឡាទីជំពូក៤ សាវ័កប៉ូលបានយកដំណើររឿងនេះ ដើម្បីមក អធិប្បាយ។ លោកប្រៀបធៀបដំណើរនាងហាការហើយនិងពូជពង្សរបស់នាងទៅនឹងភ្នំស៊ីណាយដែលជាកន្លែងលោកម៉ូសេទទួលយកក្រិត្យវិន័យ។ មិនតែប៉ុណ្ណោះ សាវ័កប៉ូលមានប្រសាសន៍អំពីឥទ្ធិពលព្រមទាំងបន្ទុកនៃក្រិត្យវិន័យដែលបានទទួលនៅភ្នំស៊ីណាយនោះ។រួចហើយលោកបានបរិយាយអំពីដំណើរនាងសារ៉ាយថាជាពូជរបស់មនុស្សដែលមានសេរីភាព។មានសេរីភាពគឺរួចពីបន្ទុកក្រិត្យវិន័យក្លាយមកជាជនមាន រួចពីចំណងដោយសារជំនឿ។ មានមនុស្សជាច្រើនណាស់សព្វថ្ងៃនេះចង់តែនៅក្រោម បន្ទុកក្រិត្យវិន័យ។ ប៉ុន្តែមិត្តសម្លាញ់ទាំងអស់អើយ ក្នុងនាមយើងជាអ្នកជឿយើងទាំងអស់គ្នាបានភ្ជាប់ឈាមជាមួយនឹងព្រះយេស៊ូវគ្រីស្ទហើយ។ក្រុមជំនុំព្រះអង្គជាគូដណ្តឹងរបស់ព្រះយេស៊ូវគ្រីស្ទហើយសាវ័កប៉ូលបញ្ជាក់ថាថ្ងៃមួយក្រុមជំនុំនឹងក្លាយត្រឡប់ទៅជាភរិយាថ្មោងថ្មីរបស់ព្រះអង្គ។ ដូច្នេះ ខ្ញុំសូមនិយាយទៅកាន់បងប្អូននៅថ្ងៃនេះថាសូមបងប្អូនកុំចង់ទទួលក្រិត្យវិន័យមកធ្វើអ្វី។បងប្អូនមិនចាំបាច់ត្រូវការនៅក្រោមក្រិត្យវិន័យតទៅទៀតទេ ពោលគឺមិនចាំធ្វើដូចជានាងហាការ ដែលរស់នៅក្រោមក្រិត្យវិន័យ ដែរ។

ដំណើររឿងនាងហាការនេះ ធ្វើអោយនាងសារ៉ាយមានការសោកសៅខ្លាំង ណាស់ ប៉ុន្តែមិនមែនគ្រាន់តែចំពោះសារ៉ាយម្នាក់ឯងប៉ុណ្ណោះទេ។អ្នកដែលទទួលការសោកសៅខ្លាំងជាងគេនោះ គឺលោកអ័ប្រាហាំ។ ពេលនេះនាងហាការបានត្រឡប់ទៅ ផ្ទះវិញដូចទេវតាបានប្រាប់ហើយនាងក៏សម្រាលបានកូនប្រុសមួយដែលត្រូវជាកូន បង្កើតរបស់លោកអ័ប្រាហាំ។



Page **3** of **15**

**ទេវតានៃព្រះយេហូវ៉ាមានបន្ទូលនឹងនាងទៀតថា មើល ឯងមាន ទំងន់ ឯងនឹងបង្កើតបានកូនប្រុស១ដែលត្រូវអោយឈ្មោះថា អ៊ីសម៉ាអែលពីព្រោះព្រះយេហូវ៉ាទ្រង់ជ្រាបពីសេចក្តីទុក្ខលំបាករបស់ឯង វានឹងបានដូចជាលាព្រៃនៅកណ្តាលមនុស្ស ដៃវានឹង បានទាស់នឹងមនុស្សទាំងអស់ ហើយដៃមនុស្សទាំងអស់ នឹងបាន ទាស់នឹងវាដែរ វានឹងតាំងទីលំនៅ នៅមុខពួកបងប្អូនវាទាំងអស់ គ្នាលោកុប្បត្តិ១៦:១១-១២។**

កំពុងដែលលោកអ្នកបងប្អូនពិចារណាខគម្ពីរខាងលើនេះ តើបងប្អូនដែលបាន គិតដែរទេថា មានការអ្វីខ្លះកើតឡើងក្នុងរយៈពេល៤០០០ឆ្នាំ នៅក្នុងប្រវត្តិសាស្រ្តរបស់ មនុស្សលោកនៅមជ្ឈឹមបូព៌ា? តើមានហេតុការណ៍អ្វីកើតឡើងនៅទីនោះក្នុងពេលសព្វថ្ងៃនេះ?ពូជពង្សរបស់អ៊ីសម៉ាអែលប្រៀបដូចជា លាព្រៃនៅកណ្តាលមនុស្ស។អស់រយៈពេលរាប់សតវត្សរ៍មកហើយមានកុលសម្ព័ន្ធមួយក្រុមតាំងទីលំ នៅនៅទីនោះ។ ការណ៍នេះ ជាការសម្រេចសេចក្តីទំនាយរបស់ព្រះជាម្ចាស់ដែលទ្រង់បានមានបន្ទូល ក្នុងខខាងលើនេះ។ ពួកមនុស្សដែលរស់នៅក្នុងកុលសម្ព័ន្ធនេះបានអះអាងថា ខ្លួនជាកូន របស់អ័ប្រាហាំ ក៏ជាកូនរបស់អ៊ីសម៉ាអែលដែរ។ ពួកជនទាំងនោះជាប់ខ្សែស្រឡាយជា មួយអ័ប្រាហាំដោយសារអ៊ីសម៉ាអែល។

**នោះនាងក៏ហៅព្រះនាមព្រះយេហូវ៉ា ដែលកំពុងមានបន្ទូលនឹង នាងថា “ព្រះដ៏ទតឃើញ” ដ្បិតនាងគិតថា នៅទីនេះអញបាន ឃើញព្រះដែលទ្រង់ទតឃើញអញទេតើ ហេតុនោះបានជាគេ ហៅក្បាលទឹកនោះថា ក្បាលទឹកឡាហាយ-រយ នោះនៅ កណ្តាល កាដែសនិងបារេឌ លោកុប្បត្តិ១៦:១៣-១៤។**


Page 4 of 15

ព្រះជាម្ចាស់ផ្តល់ព្រះគុណយ៉ាងខ្លាំងដល់នាងហាការ,នាងហាការមិនមានផ្លូវជ្រើសរើសក្នុងការចូលរួមធ្វើបាបនេះទេ។ដូច្នេះហើយបានជាព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យផ្តល់ព្រះគុណដល់នាងបន្ថែមទៀត។ខ្ញុំសូមនិយាយម្តងទៀតថាខ្ញុំជឿថាទេវតារបស់ព្រះជាម្ចាស់ដែលទៅជួយនាងហាការនោះមិនមែនជាអង្គណាក្រៅពី ព្រះគ្រីស្ទ មុនដែលព្រះអង្គយាងមកប្រសូតនៅលើផែនដីនេះទេ។ ព្រះអង្គនេះឯង ដែលយាងទៅស្វែងរកមនុស្សបាត់បង់។ ព្រះអង្គប្រៀបដូចជាអ្នកឃ្វាលហ្វូងចៀម បានជាទ្រង់នាំដំណឹងល្អនេះអោយទៅដល់នាងហាការ។

“រួចនាងក៏ហៅព្រះនាមព្រះយេហូវ៉ាដែលកំពុងមានបន្ទូលនឹងនាងថា ព្រះដ៏ ទតឃើញ”។ បទពិសោធន៍ដែលនាងជួបជាមួយនឹងព្រះពេលនេះ ជាហេតុការណ៍ថ្មី សុទ្ធសាធសម្រាប់រូបនាង ពីព្រោះនាងមិនដែលស្គាល់ការនេះពីមុនមកទេ។ សាសន៍ អេស៊ីព្ទគេមានគំនិតផ្សេងៗស្តីអំពីព្រះ។ ដ្បិតនាងគិតថា“នៅទីនេះអញបានឃើញព្រះដែលទតឃើញអញទេតើ”។នាងហាការមានចិត្តរំភើបខ្លាំងណាស់ដ្បិតនាងដឹងថាព្រះជាម្ចាស់បានទតឃើញនាង។សព្វថ្ងៃនេះយើងស្គាល់ព្រះហើយមិនសូវជាមានគំនិត រំភើបប៉ុន្មានទេ ដ្បិតយើងយល់ថា យើងស្គាល់ព្រះជាម្ចាស់គ្រាន់បើជាងនាងហាការ។ ប៉ុន្តែសូមកុំអាលទាន់អួតពីដំណើរនេះ,យើងគ្រប់រូបប្រហែលជាមិនទាន់ស្គាល់ព្រជាម្ចាស់ស្មើនឹងនាងហាការនៅឡើយទេដឹង។យើងគ្រប់រូបសុទ្ធតែជាមនុស្សប្រចុច្ចជនពិបាកនឹងស្គាល់ព្រះដែលធំហួសប្រមាណលើសពីគំនិតដែលយើងអាចស្គាល់បាន។ ខ្ញុំគិត ថាយើងគ្រប់គ្នាសុទ្ធតែមិនបានយល់ មិនបានដឹងពីព្រះអោយច្បាស់ណាស់ណាទេ។សព្វថ្ងៃនេះដរាបណាយើងមិនទាន់ទៅនៅក្នុងស្ថានអស់កល្ប យើងទាំងអស់គ្នាតែងតែ និយាយជានិច្ចថា យើងចង់ស្គាល់ព្រះជាម្ចាស់ណាស់។ ការស្គាល់ព្រះគឺជាកិរិយាខ្ពង់ ខ្ពស់បំផុត ពីព្រោះការស្គាល់ព្រះនេះ បានធ្វើអោយមនុស្សលោកមានកន្លែងរស់នៅយ៉ាងឧដុង្គឧត្តមតាំងពីអស់កល្បដល់អស់កល្បនៅឯព្ធដ៏ស្ថានសួគ៌ា។



Page **5** of **15**

**ហាការក៏បង្កើតកូនប្រុស១ឱ្យអាប់រ៉ាមហើយអាប់រ៉ាមឱ្យកូនដែលហាការបង្កើតនោះឈ្មោះអ៊ីសម៉ាអែល គ្រាដែលហាការបានបង្កើ តអ៊ីសម៉ាអែលនោះអាប់រ៉ាម គាត់អាយុបាន៨៦ឆ្នាំហើយ លោកុប្បត្តិ ១៦:១៥-១៦។**

សូមលោកអ្នកចាំថាអ៊ីសម៉ាអែលជាកូនប្រុសដំបូងរបស់អ័ប្រាហាំហើយនៅពេលដែលបានកូនប្រុសនោះ លោកអ័ប្រាហាំមានអាយុ៨៦ឆ្នាំហើយ។

## សេចក្ដីល្បងដល់លោកអ័ប្រាហាំ

មុននឹងយើងសិក្សាបន្តទៅទៀតខ្ញុំសូមធ្វើសេចក្ដីសង្ខេបនៃហេតុការណ៍ដែលព្រះជាម្ចាស់បានបើកសម្ដែងទាំង៧លើកដល់លោកអ័ប្រាហាំ។ ក្នុងចំណោមការបើក សម្ដែងទាំង៧លើកនោះ ៥ដងយើងបានឃើញរួចមកហើយ។ឯពីរដងទៀតមិនទាន់កើតមកនៅឡើយទេ។ឆ្លងកាត់ហេតុកាណ៍ទាំង៧យ៉ាងនោះ យើងឃើញថា មានពេល ដែលលោកអ័ប្រាហាំទទួលបរាជ័យ ប៉ុន្តែមានពេលដែលលោកក៏ទទួលជោគជ័យយ៉ាងត្រចះត្រចង់ផងដែរ។ឯសេចក្ដីទាំង៧យ៉ាងនេះមានដូចតទៅ។

ទី១ ព្រះជាម្ចាស់បានត្រាស់ហៅលោកអ័ប្រាហាំអោយចេញពីទីក្រុងអ៊ើរនៃ ប្រទេសខាល់ដេ ដែលជាលំនៅដ្ឋានរបស់លោក ឯអ័ប្រាហាំបានឆ្លើយតបនឹងការត្រាស់ ហៅនេះ បានមួយកំរិតធំ។ លោកមានជំនឿខ្សោយណាស់ហើយក៏មិនទាន់គ្រប់ល័ក្ខណ៍ផងប៉ុន្តែយ៉ាងហោចណាស់លោកបានចេញពីស្រុកកំណើតតាមការត្រាស់ហៅរបស់ព្រះអង្គ។នៅទីបំផុតលោកអ័ប្រាហាំបានមកដល់ទឹកដីកាណានដោយសុវត្ថិភាព ហើយនៅទីនោះព្រះជាម្ចាស់ប្រទានពរដល់លោក។

ទី២នៅក្នុងទឹកដីកាណាន មានកើតទុរ្ភិក្ស ហើយហេតុការណ៍នោះបណ្ដាល អោយអ័ប្រាហាំចាកចេញពីទឹកដីកាណានទៅតាំងទីលំនៅបណ្ដោះអាសន្ននៅប្រទេស អេស៊ីព្ទ។ នៅប្រទេសអេស៊ីព្ទ



Page **6** of **15**

លោកទទួលបានទ្រព្យសម្បត្តិជាច្រើនបរិបូរព្រមទាំងអ្នកបម្រើស្រីម្នាក់ឈ្មោះហាការ។របស់ទាំងពីរដែលលោកទទួលបាននោះ សុទ្ធតែ ជាថ្មជំពប់សម្រាប់លោកតែម្តង។

ទី៣ ព្រះជាម្ចាស់ប្រទានទ្រព្យសម្បត្តិអោយលោកអ័ប្រាហាំដើម្បីជាការសាក ល្បងដល់លោក។ និយាយពីដំណើរទ្រព្យធននេះ គ្មានមនុស្សណាម្នាក់ដែលអាចគេចរួច ពីរឿងជំពប់បាននោះទេ។ បើតាមគំនិតខ្ញុំវិញ ខ្ញុំចង់តែអោយព្រះជាម្ចាស់សាកល្បង អោយខ្ញុំមានទ្រព្យសម្បត្តិច្រើនចុះ ជាជាងអោយព្រះអង្គសាកល្បងជាមួយនឹងអ្នកដ៏ទៃ។ប៉ុន្តែខ្ញុំតែងតែសង្កេតឃើញថាព្រះជាម្ចាស់មិនទុកចិត្តខ្ញុំទេបានជាទ្រង់មិនអោយខ្ញុំមានទ្រព្យសម្បត្តិច្រើន។លោកអ័ប្រាហាំមិនបានភ្លេចព្រះដោយសារតែលោកជាអ្នកមាន នោះទេ លោកជាមនុស្សដែលមានចិត្តល្អហើយសប្បុរសជានិច្ច ជាអាទិ៍ចំពោះក្មួយរបស់លោកឈ្មោះឡុត។ប៉ុន្តែទ្រព្យសម្បត្តិដ៏ច្រើនរបស់លោកនេះហើយដែលជាកត្តាញ៉ាំងអោយលោកបែកចេញពីក្មួយរបស់លោក។ឯការល្អដែលកើតដល់លោកគឺក្រោយពីបានបែកចេញពីឡុតហើយព្រះជាម្ចាស់បានបើកសម្តែងអោយលោកឃើញ សារជាថ្មីម្តងទៀត។

ទី៤ព្រះជាម្ចាស់បានប្រទានអោយលោកអ័ប្រាហាំមានអំណាចដើម្បីច្បាំងឈ្នះស្តេចទាំងប៉ុន្មាននៅស្រុកខាងកើត។អំណាចនេះជាសេចក្តីល្បួងលយ៉ាងខ្លាំងចំពោះរូបលោក។ប៉ុន្តែនៅក្នុងពេលដែលលោកបានទទួលូអំណាចនោះ មានសង្ឃម្នាក់ ឈ្មោះម៉ិលគីស្សាដែក បានយាងទៅជួបលោក។ ជំនួបរវាងសង្ឃម៉ិលគីស្សាដែកនឹងអ័ប្រាហាំជួយរំឭកលោកដើម្បីមិនអោយលោកព្រមទទួលយកជ័យភ័ណ្ឌពីស្តេចទីក្រុង សូដុំមឡើយ។ ក្រោយពីនោះមកព្រះជាម្ចាស់បានបើកសម្តែងអង្គទ្រង់អោយលោកឃើញព្រមទាំងលើកទឹកចិត្តលោកថែមទៀតផង។

ទី៥ព្រះជាម្ចាស់ពន្យាពេលក្នុងការប្រទានកូនប្រុស១អោយលោកអ័ប្រាហាំនិងភរិយាលោកគឺជាសារ៉ាយ។លោកអ័ប្រាហាំខ្វះការអត់ធ្មត់ហើយលុះទៅតាមដំបូន្មានរបស់ប្រពន្ធផងគាត់ក៏សម្រេចធ្វើយកប្រពន្ធចុងខុសពីបំណងព្រះហឫទ័យរបស់ព្រះ។ជាលទ្ធផលអ៊ីសម៉ាអែលជាកូនប្រុសបានកើតឡើងតាមរយៈប្រពន្ធចុងរបស់លោក។សព្វថ្ងៃនេះប្រជាជនអារ៉ាប់តែងតែសង្កៀតធ្មេញជាមួយនឹងជនជាតិអ៊ី


Page 7 of 15

ស្រាអែលជានិច្ច ហើយហេតុការណ៍នេះ នឹងនៅតែរបៀបនោះរៀងរហូតលុះត្រាដល់ពេលព្រះយេស៊ូវយាងត្រឡប់មកវិញ។

ចំណែកឯសេចក្តីល្បងលពីរយ៉ាងទៀតដែលកើតឡើងដល់អ័ប្រាហាំគឺទី៦ការបំផ្លាញក្រុងសូដុំម និងកូម៉ូរ៉ាក្នុងជំពូក១៨ហើយទី៧គឺកាលដែលព្រះជាម្ចាស់សូមអោយលោកយកកូនប្រុសលោកតែមួយឈ្មោះអ៊ីសាក់ទៅធ្វើជាយញ្ញបូជានៅក្នុងជំពូក២២។

## ជំពូក ១៧

*បាវចនា ព្រះជាម្ចាស់ប្រទានអោយអ័ប្រាហាំមានឈ្មោះថ្មី ការតាំងសញ្ញា*
*របស់ព្រះជាមួយលោកអ័ប្រាហាំ កេរ្តិ៍មតករបស់អ៊ីសម៉ាអែល។*

មានមនុស្សជាច្រើនយល់ថាជំពូក១៧នេះគឺជាជំពូកសំខាន់មួយ ដែរនៅក្នុង ព្រះគម្ពីរលោកុប្បត្តិ ពីព្រោះនៅក្នុងជំពូកនេះព្រះជាម្ចាស់បានធ្វើកិច្ចសន្យាជាមួយនឹងអ័ប្រាហាំដើម្បីបញ្ជាក់ប្រាប់លោកម្តងទៀតថាលោកនឹងបានកូនប្រុសមួយប្រាកដមែន។ព្រះជាម្ចាស់បានមានបន្ទូលមកកាន់លោកអ័ប្រាហាំអោយដឹងថា អ៊ីសម៉ាអែលមិន មែនជាកូនដែលព្រះជាម្ចាស់សន្យាអោយមកលោកនោះទេ។ បើនិយាយក្នុងន័យសន្យា នេះជំពូក១៧នេះគឺជា គន្លឹះសម្រាប់អោយយល់ព្រះគម្ពីរលោកុប្បត្តិ ហើយក៏ជាគន្លឹះ សម្រាប់អោយយល់ព្រះគម្ពីរទាំងមូលផងដែរ។ កិច្ចសន្យាដែលព្រះជាម្ចាស់បានធ្វើជាមួយនឹងអ័ប្រាហាំនោះ ទាក់ទងនឹងសេចក្តីពីរយ៉ាង ១គឺពូជ ២គឺស្រុក។ ព្រះអម្ចាស់បើកសម្តែងមកអ័ប្រាហាំអោយស្គាល់ព្រះអង្គថា ទ្រង់នាមអែលស្ឆាដាយ ដែលប្រែថា “ព្រះដ៏មានព្រះចេស្តា”ព្រមទាំងព្រះអង្គប្រទានឈ្មោះថ្មីដល់លោកអ័ប្រាហាំ។តាំងពីដើមមកទល់នឹងពេលនេះឈ្មោះលោកនៅតែអាប់រ៉ាម ប៉ុន្តែចាប់ពីពេលនេះតទៅឈ្មោះលោក ប្តូរទៅជាអ័ប្រាហាំវិញ។ អាប់រ៉ាមមានន័យថា ឪពុកឧដុង្គឧត្តម ប៉ុន្តែអ័ប្រាហាំវិញមាន ន័យថា ឪពុករបស់មនុស្សទាំងហ្វូង។


Page 8 of 15

អ៊ីសម៉ាអែលមិនមែនជាកូនដែលព្រះសន្យាជា មួយនឹងលោកអ័ប្រាហាំនោះទេ ហើយជំពូក១៧នេះ បានបញ្ជាក់រឿងនេះសារជាថ្មី ដើម្បីអោយបានរឹតតែច្បាស់ទៅទៀត។

## ព្រះជាម្ចាស់ប្រទានអោយអ័ប្រាហាំមានឈ្មោះថ្មី

> **លុះដល់អាប់រ៉ាមអាយុបាន៩៩ឆ្នាំ នោះព្រះយេហូវ៉ាទ្រង់លេចមក ឯគាត់ប្រាប់ថា អញជាព្រះដ៏មានគ្រប់ព្រះចេស្តាចូរឯងដើរ នៅមុខអញ ហើយអោយបានគ្រប់ល័ក្ខណ៍ចុះ លោកុប្បត្តិ១៧៖១។**

សូមលោកអ្នកបងប្អូនគិតចុះ លោកអ័ប្រាហាំមានអាយុ៨៦ឆ្នាំពេលដែលអ៊ីស- អែលកើតមក លុះ១៤ឆ្នាំក្រោយមកទើបអ៊ីសាក់ជាកូនសន្យានោះបានកើតឡើង។“នោះព្រះយេហូវ៉ាលេចមកហើយក៏ប្រាប់ថា អញជាព្រះគ្រប់ចេស្តា ចូរឯង ដើរនៅមុខអញហើយអោយបានគ្រប់ល័ក្ខណ៍ចុះ”។ ព្រះជាម្ចាស់មានបន្ទូលថា ឈ្មោះ អញដែលអោយឯងឃើញឥឡូវនេះគឺអែលស្ហាដាយមានន័យថា “ព្រះដែលមានចេស្តា” ហើយនាមនេះមានលក្ខណៈថ្មីសុទ្ធនៅចំពោះលោកអ័ប្រាហាំ។

> **នោះអញនឹងតាំងសញ្ញានឹងឯង ហើយនិងចម្រើនឯងអោយមាន គ្នាជាសន្ធឹកឡើង លោកុប្បត្តិ១៧:២។**

នៅក្នុងមួយជំពូកនេះទាំងមូលមាននិយាយពាក្យតាំងសញ្ញាដល់ទៅ១៣ដង។ពាក្យនេះមាន និយាយ១៣ដងក្នុងមួយជំពូកនេះដែលមានតែ២៧ខប៉ុណ្ណោះ។ចំណុចនេះមានន័យថាព្រះអង្គសង្កត់ធ្ងន់ទៅលើអត្ថរសនៃការតាំងសញ្ញានេះ។នៅក្នុងជំពូក១៧ព្រះជាម្ចាស់បានបើកសម្តែងអោយលោកអ័ប្រាហាំឃើញជាលើកទី៥ហើយ។នៅលើកនេះព្រះអង្គមិនមែនគ្រាន់តែធ្វើការតាំងសញ្ញាជាមួយ



Page **9** of **15**

អ័ប្រាហាំប៉ុណ្ណោះទេប៉ុន្តែព្រះអង្គបញ្ជាក់ជាមួយលោកអ័ប្រាហាំម្តងទៀតថាលោកនឹងបានកូនប្រុសមួយ ហើយកូននោះ ឯង ជាអ្នកគ្រងមរតក មិនមែនអ៊ីសម៉ាអែលនោះទេ។

សាវ័កប៉ូលបានពន្យល់ដំណើររឿងនេះនៅក្នុងព្រះគម្ពីររ៉ូមយ៉ាងដូច្នេះថា“ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿបានជាលោកមិនគិតពីរូបកាយលោកដែលរាប់ដូចជាស្លាប់ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ”រ៉ូម៤៖១៩។ ផ្ទៃរបស់នាងសារ៉ាប្រៀបដូចជាផ្នូរដែល គ្មានជីវិត ប៉ុន្តែមានជីវិតមួយបានប្រសូតឡើងគឺអ៊ីសាក់។ សាវ័កប៉ូលសរុបសេចក្តីនៅ ក្នុងជំពូក៤ថាដំណើរនេះ បញ្ជាក់ពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ “ដែលទ្រង់ត្រូវគេ បញ្ជូនទៅអោយមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសអោយមានព្រះជន្មរស់ឡើងវិញប្រយោជន៍អោយយើងរាល់គ្នាបានរាប់ជា សុចរិត”រ៉ូម៤៖២៥។ ខ្លឹមសារនៃការតាំងសញ្ញាដែលព្រះជាម្ចាស់ធ្វើជាមួយនឹងលោកអ័ប្រាហាំនៅពេលនេះគឺមានជីវិតដុះឡើងចេញពីសេចក្តីស្លាប់។ ពេលនេះលោក អ័ប្រាហាំអាយុ៩៩ឆ្នាំហើយ ឯនាងសារ៉ាយវិញ អាយុ៨៩ឆ្នាំដែរ។ ដូច្នេះពេលដែល អ៊ីសាក់កើតមក លោកអ័ប្រាហាំមានអាយុ១០០ឆ្នាំ រីឯនាងសារ៉ាយមានអាយុ៩០ឆ្នាំ។

**អាប់រ៉ាមក៏ក្រាបផ្កាប់មុខរួចព្រះទ្រង់មានបន្ទូលនឹងគាត់ថាឯអញ**
**មើលអញបានតាំងសេចក្តីសញ្ញានឹងឯងហើយ ឯងនឹងធ្វើជា ឪពុកនៃសាសន៍ជាច្រើន**
**លោកុប្បត្តិ១៧:៣_៤។**

ព្រះជាម្ចាស់មានបន្ទូលថា លោកអ័ប្រាហាំនឹងក្លាយជាឪពុកនៃសាសន៍ជា ច្រើន។ ខ្ញុំយល់ថា លោកអ័ប្រាហាំមានកូនច្រើនជាងមនុស្សណាទាំងអស់ដែលធ្លាប់រស់នៅលើលោកយើងនេះ។សូមគិតមើលតើមែនឬមិនមែន៖ក្នុងរយៈពេល៤០០០ឆ្នាំកន្លងមកនេះមានខ្សែស្រឡាយពីរដែលសាយភាយខ្លាំងមែនទែនពោលគឺខ្សែស្រឡាយអ៊ីសម៉ាអែលនិងខ្សែស្រឡាយអ៊ីសាក់ហើយខ្សែស្រឡាយរបស់បុគ្គល


Page **10** of **15**

ទាំងពីររូបនេះ មានខ្សែស្រឡាយរាប់ពាន់ជាបន្តទៅទៀត។ គ្រួសារនេះធំណាស់, បន្ថែមទៅលើចំនួនកូនរបស់លោកខាងសាច់ឈាមនៅមានកូនរបស់លោកខាងព្រលឹងវិញ្ញាណទៅទៀតពោលគឺលោកទាំងអស់គ្នាដែលជាគ្រីស្ទបរិស័ទដែលបានរាប់បញ្ចូលថាជាកូនរបស់ លោកអ័ប្រាហាំដោយសារមានជំនឿជឿលើព្រះយេស៊ូវគ្រីស្ទ។ នៅក្នុងព្រះគម្ពីររ៉ូម សាវ័កប៉ូលបានបញ្ជាក់ពីដំណើរអ័ប្រាហាំនេះថាលោកជា "ឪពុករបស់យើងរាល់គ្នា"រ៉ូម៤:១៦។យើងរាល់គ្នាគឺជាពួកគ្រីស្ទបរិស័ទដែលជាកូនខាងព្រលឹងវិញ្ញ

ឯកូនខាងសាច់ឈាមវិញមានអ៊ីសម៉ាអែល និងពួកអារ៉ាប់រួមគ្នាផងដែរ។ សូមបងប្អូនពិចារណាមើលពីចំនួនមនុស្សរាប់លាននាក់ដែលមានសព្វថ្ងៃនេះ។ព្រះជាម្ចាស់មានព្រះបន្ទូលក្នុងខនេះថា"ឯងនឹងធ្វើជាឪពុកនៃសាសន៍ជាច្រើន"។មនុស្សដែលលោកអ្នកបងប្អូនបានឃើញសព្វថ្ងៃមានរាប់លាននាក់នេះ ជាស្មរបន្ទាល់បញ្ជាក់ថា ព្រះជាម្ចាស់ មានសេចក្តីស្មោះត្រង់ព្រមទាំងរក្សាកិច្ចសន្យារបស់ផងទ្រង់ជានិច្ច។

**ឈ្មោះឯងមិនត្រូវហៅថាអាប់រ៉ាមទៀតទេ គឺត្រូវហៅថា អ័ប្រាហាំវិញ ដ្បិតអញបានតាំងឯងឱ្យធ្វើជាឪពុកនៃសាសន៍ជា ច្រើន លោកុប្បត្តិ១៧:៥។**

អាប់រ៉ាមមានន័យថា ឪពុកដ៏ឧដុង្គឧត្តម ឬឪពុកដែលមានកិត្តិយសខ្ពង់ខ្ពស់ ឬមួយក៏ជាឪពុកខ្ពស់បណ្តាច់។ ចំណែកអ័ប្រាហាំវិញមានន័យថា ជាឪពុកនៃសាសន៍ជា ច្រើន។

តទៅនេះខ្ញុំនឹងនិទានរឿងមួយទាក់ទងនឹងជំនឿរបស់លោកអ័ប្រាហាំ។រឿងនិទាននេះមានដូចតទៅ។ព្រឹកមួយនោះលោកអ័ប្រាហាំនិងនាងសារ៉ាយក្រោកពីដំណេកឃើញមានពួកឈ្មួញជាច្រើននាក់ធ្វើដំណើរសំដៅមកទីបោះត្រសាលរបស់គាត់ នៅក្បែរក្បាលទឹក នៅភូមិហេប្រុន។ លោកអ័ប្រាហាំចេញទៅជំរាបសួរដល់ពួកពាណិជ្ជករទាំងនោះក្រែងលោគេចង់ដងទឹកអណ្តូងដើម្បីអោយអូដ្ឋគេផឹក។



Page **11** of **15**

មនុស្សសម័យនោះ មនុស្សមានចិត្តជ្រះថ្លាចំពោះភ្ញៀវណាស់។ ត្រង់នេះយើងកំពុងនិយាយអំពីមនុស្សសម័យដើម ដែលជាមនុស្សរស់នៅក្នុងរូងភ្នំ យើងគិតថាមនុស្សសម័យនោះប្រហែលជាគ្មានអារ្យធម៌ទេហើយចិត្តក៏អាក្រក់ទ្រឹស្តស្ទូរណាស់ផង។ ប៉ុន្តែលោកអ្នកបងប្អូនអើយ ខ្ញុំសូមជំរាបលោកអ្នកយ៉ាងដូច្នេះថា នៅក្នុងសម័យនោះ បើគេឃើញមនុស្សណាម្នាក់ជាជនចំឡែកដើរកាត់ស្រុកគេ គេមិនអោយអ្នកនោះដើរ កាត់ស្រុកគេ ដោយមិនបានចូលទៅបរិភោគអាហារនៅផ្ទះរបស់គេសិននោះឡើយ។ ប៉ុន្តែតើបងប្អូនដឹងឬទេថា សព្វថ្ងៃនេះ នៅទីក្រុងដែលបងប្អូនរស់នៅសព្វថ្ងៃបើសិន មានមនុស្សណាចំឡែកចូលទៅទីក្រុងនោះ តើមាននរណាអញ្ជើញជនចំឡែកនេះ អោយចូលទៅក្នុងផ្ទះដើម្បី សម្រាកសិនដែរឬទេ ប្រពៃណីរបស់យើងសព្វថ្ងៃនេះខុសប្លែកពីប្រពៃណីរបស់មនុស្សជំនាន់ដើមឆ្ងាយណាស់។តាមបទគម្ពីរ មានសម្តែងថា នៅសម័យដើមមនុស្សចិត្តល្អណាស់ តែងតែទទួលជនចំឡែកអោយចូលទៅក្នុងផ្ទះគេជានិច្ច។

អ័ប្រាហាំចេញទៅជួបជាមួយនឹងពួកឈ្មួញទាំងនោះ ក៏សន្ទនាជាមួយនឹងគេ យ៉ាងដូច្នេះ “សូមអញ្ជើញចូលមក ហើយសម្រាកអោយបានស្រួលចាំខ្ញុំទៅដងទឹក អោយសត្វទាំងនោះផឹក”។ ពួកឈ្មួញទាំងនេះបាននិយាយត្រឡប់មកអោយអ័ប្រាហាំវិញថា“ខ្ញុំអរគុណហើយខ្ញុំមិនអាចសម្រាកបានយូរទេ គ្រាន់តែអោយទឹកអូដ្ឋផឹកប៉ុណ្ណោះ ហើយយើងប្រញាប់ទៅលក់ដូរនៅប្រទេសអេស៊ីព្ទ”។

ឈ្មួញម្នាក់នោះបានជំរាបលោកអ័ប្រាហាំថា “ខ្ញុំឈ្មោះអាឡា” ហើយឈ្មួញម្នាក់ទៀតបានណែនាំខ្លួនអោយស្គាល់លោកអ័ប្រាហាំដោយនិយាយថា “ឈ្មោះខ្ញុំអាលី បាបា”។ តើចំណែកលោកវិញឈ្មោះអ្វីដែរ? លោកអ័ប្រាហាំឆ្លើយត្រឡប់ទៅវិញថា “ខ្ញុំឈ្មោះឪពុកឧត្តម”។ ពេលអ្នកទាំងពីរឮយ៉ាងដូច្នេះក៏បានសួរត្រឡប់ទៅវិញថា តើ លោកជាឪពុករបស់កូនប្រុសឬក៏កូនស្រី លោកអ័ប្រាហាំឆ្លើយថា ខ្ញុំឥតមានកូនមួយ ទេ។ មនុស្សទាំងពីរនោះសើចហ៉ាសហា៎ រួចនិយាយទៅកាន់លោកថា“បើលោកមិនមានកូនមួយទេហេតុអ្វីបានជាឈ្មោះលោកមានន័យថាអ័ប្រាហាំ? តើនៅលើលោកនេះ មានមនុស្សប្រុសដែលមិនមានកូនហើយគេហៅថាជាឪពុកដែរឬទេ?


Page 12 of 15

ពួកទាំងនោះនាំ គ្នាសើច ហើយបញ្ជាអូដ្ឋរបស់ខ្លួនដើរកាត់ទីរហោស្ថានធ្វើដំណើរឆ្ពោះទៅប្រទេសអេស៊ីព្ទទៅ។

ប្រាំមួយខែក្រោយមកពួកឈ្មួញដដែលនេះបានត្រឡប់មកសម្រាកនៅមុំផ្ទះលោកអ័ប្រាហាំទៀត។ ពេលដែលលោកអ័ប្រាហាំចេញទៅជួបពួកឈ្មួញទាំងនោះ ពួក ឈ្មួញទាំងនោះសើចពីចម្ងាយហើយជំរាបសួរថា“ជំរាបសួរលោកឪពុកដ៏ឧដុង្គឧត្តមអើយ៎”ពេលនេះលោកអ័ប្រាហាំឆ្លើយតបទៅវិញថា “ឈ្មោះខ្ញុំមិនមែន ជាឪពុកដ៏ឧដុង្គ- ឧត្តមទៀតទេ ឥឡូវនេះខ្ញុំឈ្មោះថាជាឪពុកនៃជាតិសាសន៍ជាច្រើនវិញ”។ពួកឈ្មួញទាំងនោះឆ្លើយតបមកវិញថា“គាត់ពិតជាមានកូនភ្លោះហើយក្នុងរយៈពេល៦ខែនេះ៎”ពួកឈ្មួញទាំងនោះសើចយ៉ាងរីករាយក្អាកក្អាយប៉ុន្តែអ័ប្រាហាំឆ្លើយតបទៅវិញថា “ទេ ខ្ញុំមិនទាន់កូនមួយនៅឡើយផង” ឈ្មួញទាំងនោះឆ្លើយតបត្រឡប់មកវិញថាមនុស្សម្នាក់ នេះឡប់សតិទេដឹងបានជាឆ្លើយមិនដឹងអី៎”

ត្រង់នេះយើងឃើញថាមានមនុស្សម្នាក់ដែលរាប់ខ្លួនថាជាឪពុកតាំងតែពីមុនពេលដែលលោកមានកូនរបស់ខ្លួនទៅទៀត។ លោកអ័ប្រាហាំគឺជាលោកអ័ប្រាហាំ ហើយឈ្មោះរបស់លោកមានន័យថាជាឪពុកនៃសាសន៍ជាច្រើន។ លោកហៅខ្លួន លោកថាជាឪពុកបែបនេះ ពីព្រោះលោកជឿថានឹងមានកូនមកអោយគាត់មែន។ កាល ដែលលោកមានជំនឿនោះ មិនទាន់មានកូនច្រើននៅឡើយទេ ប៉ុន្តែ៤០០០ឆ្នាំក្រោយ មកទៀត នៅកន្លែងលោកអ្នកបងប្អូនហើយនិងខ្ញុំកំពុងអង្គុយស្តាប់មេរៀននេះ ព្រះជាម្ចាស់បានធ្វើអោយការសន្យានោះអោយសម្រេចមែន។ នាមរបស់លោកមិនប្តូរ ផ្លាស់ឡើយ ពោលគឺអ័ប្រាហាំជាឪពុកនៃសាសន៍ជាច្រើន។

## ការតាំងសញ្ញារបស់ព្រះជាម្ចាស់ជាមួយនឹងអ័ប្រាហាំ

**អញនឹងធ្វើឱ្យឯងបង្កើតកូនសុសសាយជាសន្ធឹកឱ្យមាននគរ ផ្សេងៗកើតចេញអំពីឯងមក ព្រមទាំងស្តេចជាច្រើនដែរអញនឹងតាំងសញ្ញានឹងឯងហើយនិងពូជឯងតាមដំណាគេតទៅ**


Page 13 of 15

**ទុកជា សេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ច ដើម្បីឱ្យអញបានធ្វើជាព្រះនៃឯងនិងពូជឯងតទៅ លោកុប្បត្តិ១៧:៦-៧។**

តើព្រះជាម្ចាស់បានតាំងសញ្ញាយ៉ាងដូចម្តេចជាមួយនឹងអ័ប្រាហាំ?ព្រះបានតាងសញ្ញាដ៏អស់កល្បជានិច្ចជាមួយនឹងលោក។តើការតាំងសញ្ញានេះមានប្រសិទ្ធភាពនៅក្នុងកាលៈទេសៈសព្វថ្ងៃនេះដែរឬទេ?ឯចម្លើយគឺថាប្រាកដជានៅមានប្រសិទ្ធភាពមកទល់សព្វថ្ងៃនេះ។ព្រះជាម្ចាស់បានសន្យាជាមួយលោកអ្នកបងប្អូនហើយនិងខ្ញុំអោយមានជីវិតអស់កល្បជានិច្ចបើយើងទាំងអស់គ្នាជឿដល់ព្រះយេស៊ូវគ្រីស្ទ។ នេះហើយជា ការតាំងសញ្ញាដែលព្រះទ្រង់បានធ្វើជាមួយនឹងយើង។ បងប្អូនមិត្តសម្លាញ់អើយបើ ប្រសិនណា ជាលោកអ្នកបែរជាមិនឃើញការតាំងសញ្ញាដែលព្រះបានធ្វើជាមួយនឹង លោកអ្នកមិនមានប្រសិទ្ធិភាពលោកអ្នកត្រូវឆែកឆេរមើលការតាំងសញ្ញាដែលព្រះជាម្ចាស់បានធ្វើជាមួយលោកអ្នកបងប្អូនសារជាថ្មីឡើងវិញ។កំពុងដែលលោកអ្នកឆែកឆេរមើលការតាំងសញ្ញាដែលព្រះធ្វើជាមួយនឹងលោកអ្នកឡើងវិញខ្ញុំសូមបញ្ជាក់ត្រង់នេះថាព្រះជាម្ចាស់ទ្រង់នឹងធ្វើអោយការតាំងសញ្ញាដែលទ្រង់ធ្វើជាមួយនឹងលោកអ័ប្រាហាំនេះមានប្រសិទ្ធភាពជានិច្ចជាកាលអស់កល្បតរៀងទៅ។ ការតាំងសញ្ញានេះមានប្រសិទ្ធិភាពមកលើជីវិតលោកអ្នកផ្ទាល់ដែរបើលោកអ្នកមានជំនឿលើព្រះបន្ទូលព្រះដូចលោកអ័ប្រាហាំ។



Page **14** of **15**

**-ភ្លេងចំរៀង-**

**ពិធីករប្រុស១៖**កម្មវិធីនេះផលិតឡើងដោយវិទ្យុត្រែនវែល៍សហការជាមួយThrough The Bible Network សូមលោកអ្នកបន្ត បើកស្តាប់កម្មវិធីនេះបន្តទៅទៀតចាប់ពីថ្ងៃចន្ទ័ដល់ថ្ងៃសុក្រដែលមានលោកគ្រូគង្វាល ជាគ្រូអធិប្បាយប្រចាំប្រពន្ធ័សិក្សាព្រះគម្ពីររបស់យើង។

**ពិធីករប្រុស២៖**កម្មវិធីនេះសហការជាមួយនិងកម្មវិធីជីវិតបរិសុទ្ធឬក៏ទូរសព្ទ័មកកាន់ការិល័យយើងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃចន្ទ័ដល់សុក្រឬលេខទូរសព្ទ័០១២៧៥៨៦៧៤៧៤ អ៊ីម៉ែល Adress TWR@TWR.org

សូមអរគុណសូមជំរាបលា។

**-ភ្លេងចប់----**



Page **15** of **15**